00483884

A 364

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ក្រឡាបញ្ជីសហចៅក្រមស៊ើបអង្កេតនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឈ្មោះ: លី ច័ន្ទតុលា

សោម រតនា

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 03 / 2010
ម៉ោង (Time/Heure): 09 : 15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

លេខសំណុំរឿង.: 002/19-09-2007-ECCC-OCIJ

**កម្មវត្ថុ: ស្ថានភាពនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

លោកស្រីមេធាវី Lyma Thuy NGYEN លោកមេធាវី Mahdev MOHAN និង លោកមេធាវី នី ចាន់ឌី ជាទីរាប់អាន សូមទទួលយកលិខិតរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងកូនក្តីរបស់លោក-លោកស្រីមេធាវីដែលមានលេខយោងរបស់អង្គភាពជនរងគ្រោះដូចខាងក្រោម:

08-VU-02116 (D22/172)
08-VU-02130 (D22/102)
08-VU-02267 (D122/135)
08-VU-02378 (D22/276)
08-VU-02379 (D22/125)
08-VU-02380 (D22/171)
08-VU-2291 (D22/205)
09-VU-00638 (D22/134)
09-VU-00641 (D22/101)
09-VU-00685 (D22/287)
09-VU-00686 (D22/285)
09-VU-00687 (D22/284)
09-VU-00688 (D22/286)
09-VU-01722 (D22/278)
09-VU-01723 (D22/277)
09-VU-02136 (D22/258)
09-VU-02138 (D22/260)
09-VU-02141 (D22/263)
09-VU-02142 (D22/264)
09-VU-02143 (D22/265)
09-VU-02144 (D22/266)
09-VU-02145 (D22/267
09-VU-02146 (D22/268)
09-VU-02147 (D22/269)
09-VU-02148 (D22/270)
09-VU-02150 (D22/272)
09-VU-02151 (D22/273)
09-VU-02239 (D22/282)
09-VU-02240 (D22/283)
09-VU-02241(D22/279)
09-VU-02242 (D22/280)
09-VU-02243 (D22/281)
09-VU-04265 (D22/274)

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 03 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

00483885

A364

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**OFFICE OF THE CO-INVESTIGATING JUDGES**
**BUREAU DES CO-JUGES D'INSTRUCTION**

**ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០**

លោក-លោកស្រី ជាទីរាប់អាន

បន្ទាប់ពីបានទទួល សំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក-លោកស្រី លិខិតមួយច្បាប់បានផ្ញើជូន លោក-លោកស្រី ដើម្បីជម្រាបជូនលោក-លោកស្រីថា សំណើសុំនេះ បានដាក់ទៅក្នុងសំណុំរឿង។ ការជូនដំណឹងនេះ មិនមែនជាកិច្ចយុត្តាធិការទេ ហើយសហចៅក្រម ស៊ើបអង្កេតនឹងត្រូវសម្រេចតាមរយៈដីកាសម្រេច លើការយល់ព្រមទទួលសំណើសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីទាំងនេះ យ៉ាងយូរបំផុតនៅពេលចេញដីកាដំណោះស្រាយ ។

យើងបានបានសិក្សាលើសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក-លោកស្រី ស្របតាមវិធាន ២៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក រួចហើយ។

សំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក-លោកស្រី ពិតជាមានព័ត៌មាន សំខាន់ៗនៃអំពើដែលបានប្រព្រឹត្តចន្លោះពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ពួកខ្មែរក្រហម។

ប៉ុន្តែ បទឧក្រិដ្ឋដែលលោក-លោកស្រី បានរៀបរាប់នៅក្នុងសំណើសុំរបស់ខ្លួន មិនមានការ ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងវិសាលភាពនៃការស៊ើបអង្កេត ដែលត្រូវបានកំណត់ដោយសហព្រះ រាជអាជ្ញា នៅក្នុងសំណុំរឿង ០០២ ទេ (សូមអានសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ២០០៩)។ តាមការពិត សហព្រះរាជអាជ្ញាបានបញ្ជូនមកសហចៅក្រមស៊ើបអង្កេតនូវអង្គហេតុ ដែលបានចោទប្រកាន់ ដែលមានលក្ខណៈជាក់លាក់។ សហចៅក្រមស៊ើបអង្កេតត្រូវគោរពតាម វិសាលភាពនៃអង្គហេតុដែលបានបញ្ជូនមកនេះ ហើយអនុលោមតាមវិធាន ២៣(១) នៃវិធានផ្ទៃ ក្នុង ជនរងគ្រោះនៃបទឧក្រិដ្ឋណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក អាចសុំតាំង

ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺត្រឹមតែដើម្បីចូលរួមក្នុងបណ្តឹងអាជ្ញាដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ដោយគាំទ្រដល់ការចោទប្រកាន់នៅក្នុងបណ្តឹងនោះប៉ុណ្ណោះ។ ដូច្នេះ ជនរងគ្រោះដែលអាចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីបាន លុះត្រាព្យសនកម្មដែលខ្លួនលើកឡើងមានការពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់ប៉ុណ្ណោះ។ ជាការចាំបាច់ដែលត្រូវដឹងថា សហព្រះរាជ-អាជ្ញា មិនអាចបញ្ជូនមកសហចៅក្រមស៊ើបអង្កេត នូវគ្រប់អង្គហេតុទាំងអស់ដែលអាចស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការទេ ព្រោះវាអាចបណ្តាលឱ្យមានការយឺតយ៉ាវដល់ការជំនុំជម្រះ។ ហេតុដូច្នេះ ដើម្បីជាប្រយោជន៍ទាំងអស់គ្នា និងជាពិសេសសម្រាប់ជនរងគ្រោះនោះ នីតិវិធីនាពេលបច្ចុប្បន្នត្រូវតែដំណើរការរហូតដល់ចប់ក្នុងរយៈពេលមួយសមស្រប ដើម្បីទទួលបាននូវយុត្តិធម៌ដោយមិនមានការពន្យារពេល។

ដោយហេតុថា ពាក្យសុំរបស់លោក-លោកស្រី ផ្តល់នូវវិភាគទានសំខាន់ក្នុងការបង្ហាញការពិត ដូចនេះ ពាក្យសុំនេះនឹងរក្សាទុកនៅក្នុងសំណុំរឿងជាផ្លូវការ។

សហចៅក្រមស៊ើបអង្កេត ក៏សូមគូសបញ្ជាក់ថា សេចក្តីសម្រេចមិនទទួលយកសំណើសុំរបស់លោក-លោកស្រី មិនមានន័យថា លក្ខណៈសម្បត្តិជាជនរងគ្រោះរបស់លោក-លោកស្រីដោយសារឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អង្គជំនុំជម្រះ មិនត្រូវបានទទួលស្គាល់នោះទេ។ អង្គជំនុំជម្រះនឹងប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងពាក្យសុំរបស់ លោក-លោកស្រី សម្រាប់នីតិវិធីជាបន្តទៀត។

នៅក្នុងឆ្នាំ ២០១០ នេះ សហចៅក្រមស៊ើបអង្កេត នឹងចេញដីកាមួយ ហៅថាដីកាដំណោះស្រាយ ដែលជាការបញ្ចប់ការស៊ើបសួរនាពេលនេះ។

យើងសង្ឃឹមថា ការពន្យល់ទាំងនេះ នឹងធ្វើឱ្យលោក-លោកស្រី យល់កាន់តែច្បាស់ពីសេចក្តីសម្រេចរបស់យើងលើសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីយើង។

**យូ ប៊ុនឡេង** | **Marcel LEMONDE**

*E.C.C.C * C.E.T.C * CO-JUGES D' INSTRUCTION * CO-INVESTIGATING JUDGES



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ
ទូរស័ព្ទ: ០២៣ ២១៩៨១៤ ទូរសារ: ០២៣ ២១៩៨៤១ ប្រអប់សំបុត្រ ៧១ ក្រុងភ្នំពេញ កម្ពុជា